## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៩

### សេចក្តីសំរេចលេខ ៦៧ សសរ

### ស្តីពីការបង្កើតគណៈកម្មការ សំរាប់ដោះស្រាយ បញ្ហាប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅ និងធ្វើ ការងារខុសច្បាប់ នៅប្រទេសម៉ាឡេស៊ី

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

### សំរេច

ប្រការ ១ : បង្កើតគណៈកម្មការ សំរាប់ដោះស្រាយបញ្ហាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅ និងធ្វើការងារខុសច្បាប់ នៅប្រទេសម៉ាឡេស៊ី ដែលមានសមាសភាព ដូចខាងក្រោម ៖

១-ឯកឧត្តម នឹម ចូត រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ប្រធាន

២-ឯកឧត្តម សេង លឹមនៅ អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៣-លោក ស៊ា គុសល ប្រធាននាយកដ្ឋានកុងស៊ុលនិងច្បាប់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៤-លោក ឌី សុខថាន អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ សមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ច ៖

-ធ្វើទំនាក់ទំនងជាមួយអាជ្ញាធរជាតិមានសមត្ថកិច្ច ដើម្បីរៀបចំទំរង់បែបបទនិងនីតិវិធី ដើម្បីការធ្វើមាតុភូមិនិវត្តន៍

-ធ្វើទំនាក់ទំនងជាមួយអាជ្ញាធរមានសមត្ថកិច្ចម៉ាឡេស៊ី ដើម្បីរកដំណោះស្រាយបញ្ហាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅ និងធ្វើការងារខុសច្បាប់នៅប្រទេសម៉ាឡេស៊ី

-ធ្វើរបាយការណ៍អំពីវិធានការដែលពាក់ព័ន្ធនឹងការចូលរួមនៃការពង្រឹងលើជួររាជរដ្ឋាភិបាល ។

**ប្រការ ៣ ៖** សមាជិកគណៈកម្មការនេះ ត្រូវជួបប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន និងសាមីខ្លួន ដែលមានចែងឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៩

## សេចក្តីសម្រេចលេខ ៦៨ សសរ

## ស្តីពីការ បើកថ្នាក់បរិញ្ញាបត្រគ្រប់មុខវិជ្ជាសិក្សា

## តាមប្រព័ន្ធបង់ថ្លៃនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ ១ ៖** អនុញ្ញាតអោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បើកថ្នាក់បរិញ្ញាបត្រ សិក្សាតាមប្រព័ន្ធបង់ថ្លៃចាប់ពី ឆ្នាំសិក្សា ១៩៩៨-១៩៩៩ នេះតទៅ ។